E403

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 05 / 2016
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

**អង្គជំនុំជម្រះសាលាដំបូង**

ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសាក្សី 2-TCW-876 និង ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-234**

១. អង្គជំនុំជម្រះសាលាដំបូងបានជ្រើសយកសាក្សី 2-TCW-876 និង ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-234 ឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ទាក់ទិននឹងអង្គហេតុទំនប់ត្រពាំងថ្ម និង ការប្រព្រឹត្តិលើជនជាតិវៀតណាម។ ទោះបីយ៉ាងណាក៏ដោយ ដូចបានបញ្ជាក់លម្អិតបន្ថែមទៀតខាងក្រោម អង្គជំនុំជម្រះមិនអាចធានាឱ្យមានវត្តមានរបស់ពួកគាត់ចំពោះមុខ អ.វ.ត.ក បានឡើយ អាស្រ័យហេតុនេះ អង្គជំនុំជម្រះជូនដំណឹងដល់ភាគីទាំងអស់អំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងការសម្រេចមិនកោះហៅបុគ្គលទាំងនេះទៀត។

*សាក្សី 2-TCW-876*

២. នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-876 ក្នុងអំឡុងសវនាការលើអង្គហេតុស្តីពីការដ្ឋានការងារទំនប់ត្រពាំងថ្ម (សូមមើល អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥)។ នៅថ្ងៃទី ១០ ខែ សីហា មួយថ្ងៃមុនថ្ងៃចូលបង្ហាញខ្លួនរបស់គាត់តាមការកំណត់នោះ សាក្សី 2-TCW-876 មានបញ្ហាបន្ទាន់មិនអាចមកផ្តល់សក្ខីកម្មបានទេ (ប្រតិចារឹកសវនាការ ថ្ងៃទី

១០ ខែ សីហា ឆ្នាំ ២០១៥ ទំព័រ ១-២)។ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សាក្សីរូបនេះមិនមានលទ្ធភាពមកផ្តល់សក្ខីកម្មក្នុងអំឡុងសវនាការលើអង្គហេតុការដ្ឋានការងារទំនប់ត្រពាំងថ្មបានទេ។ ភាគីទទួលបានការជូនដំណឹងបន្ថែមទៀតថា ប្រសិនបើសាក្សី 2-TCW-876 អាចចូលមកផ្តល់សក្ខីកម្មបាននៅដំណាក់កាលក្រោយទៀតនោះ អង្គជំនុំជម្រះនឹងពិចារណាថាតើ ត្រូវកំណត់កាលបរិច្ឆេទឡើងវិញដើម្បីស្តាប់សក្ខីកម្មគាត់ ឬ យ៉ាងណា (សូមមើលអ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥។ សូមមើលផងដែរ អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥)។

៣. នៅក្នុងខែ មេសា ឆ្នាំ ២០១៦ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានដាក់របាយការណ៍មួយជូនអង្គជំនុំជម្រះ ដោយបានបញ្ជាក់អំពីមូលហេតុដែលសាក្សីរូបនេះមិនមានលទ្ធភាពចូលមកផ្តល់សក្ខីកម្មបាននៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥។ អង្គជំនុំជម្រះកត់សម្គាល់ថាបុគ្គលិករបស់អង្គភាពគាំពារសាក្សី និង អ្នកជំនាញបានទៅយកសាក្សី 2-TCW-876 ពីផ្ទះរបស់គាត់ នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ មកកាន់ អ.វ.ត.ក ដើម្បីឱ្យផ្តល់សក្ខីកម្មនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥។ ខណៈដែលកំពុងធ្វើដំណើរនោះ សាក្សី 2-TCW-876 បានប្រាប់ថាមានអារម្មណ៍តានតឹង ហើយនៅពេលមកដល់ខេត្តពោធិ៍សាត់ ស្ថានភាពរបស់គាត់កាន់តែយ៉ាប់យ៉ឺនទៅៗមួយរំពេច។ ឃើញដូច្នេះ បុគ្គលិករបស់អង្គភាពគាំពារសាក្សី និង អ្នក-ជំនាញ បាននាំយកសាក្សីទៅឱ្យវេជ្ជបណ្ឌិតពិនិត្យនៅមន្ទីរពេទ្យខេត្ត។ បន្ទាប់ពីពិនិត្យរួចហើយវេជ្ជបណ្ឌិតបានប្រាប់អង្គភាពគាំពារសាក្សី និង អ្នកជំនាញថា សាក្សី 2-TCW-876 គឺជាអ្នកពិសាស្រារាល់ថ្ងៃ ដែលទើបតែឈប់ពិសាស្រារយៈពេល៣ថ្ងៃ មុនពេលធ្វើដំណើរទៅកាន់តុលាការដើម្បីត្រៀមផ្តល់សក្ខីកម្ម។ វេជ្ជបណ្ឌិតបានសន្និដ្ឋានថា សាក្សីរូបនេះមានអាការធ្វើទុក្ខក្នុងខ្លួនខ្លាំង ដោយសារទើបតែឈប់ពិសាស្រាភ្លាមៗ។ សាក្សីរូបនេះត្រូវស្ថិតនៅក្រោមការពិនិត្យតាមដានមួយយប់នៅឯមន្ទីរពេទ្យ ហើយព្រឹកឡើងក៏ត្រូវបានអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យ ដោយវេជ្ជបណ្ឌិតផ្តល់អនុសាសន៍មិនឱ្យបន្តដំណើរទៅរាជធានីភ្នំពេញឡើយ តែត្រូវវិលត្រឡប់ទៅផ្ទះវិញ ហើយគាត់គួរតែស្វែងរកការព្យាបាលផ្នែកវេជ្ជសាស្ត្រ រយៈពេលយ៉ាងតិចបីសប្តាហ៍។

៤. ដោយអនុវត្តតាមអនុសាសន៍របស់វេជ្ជបណ្ឌិត អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានបន្តចុះតាមដានសាក្សីជាច្រើនលើកដើម្បីឱ្យធ្វើការវាយតម្លៃថាតើ គាត់កំពុងទទួលការព្យាបាល

ផ្នែកវេជ្ជសាស្ត្រដែរ ឬទេ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានទទួលដំណឹងថា សាក្សី 2-TCW-876 មិនបានបន្តព្យាបាលផ្នែកវេជ្ជសាស្ត្រទេ ដោយសារតែបញ្ហាថ្លៃចំណាយ (ឯកសារ E29/483 របាយការណ៍របស់អង្គភាពគាំពារសាក្សី និង អ្នក-ជំនាញ)។

៥. អង្គជំនុំជម្រះយល់ឃើញថា សាក្សីរូបនេះមានអាការញៀនស្រាពុំរ៉ៃ និង អាការធ្វើទុក្ខក្នុងខ្លួនខ្លាំងពាក់ព័ន្ធនឹងការឈប់ពិសាស្រា ដែលប្រការនេះប៉ះពាល់ដល់សម្បទារបស់សាក្សីក្នុងការផ្តល់សក្ខីកម្ម។ ដោយកត់សម្គាល់ឃើញបន្ថែមទៀតអំពីហានិភ័យផ្នែកសុខភាពធ្ងន់ធ្ងរទាក់ទិននឹងស្ថានភាពនេះ និង ការណ៍ដែលសាក្សីមិនបានស្វះស្វែងរកការព្យាបាលសុខភាពគាត់ ព្រមទាំងប្រការដែលអង្គជំនុំជម្រះមិនអាចចាត់ចែងការព្យាបាលណាមួយទៅលើរូបគាត់បាន អង្គ-ជំនុំជម្រះយល់ឃើញថា ការដកសាក្សីរូបនេះចេញពីបញ្ជីឈ្មោះសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់អង្គហេតុការដ្ឋានការងារទំនប់ត្រពាំងថ្ម គឺជាការសមស្រប។

*ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-234*

៦. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ មេធាវីការពារក្តី នួន ជា បានលើកឡើងនូវបញ្ហាពាក់ព័ន្ធនឹងភាពគួរឱ្យជឿជាក់បាននៃដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-300 ដែលធ្លាប់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ កាលពីថ្ងៃទី ០២ និងទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ទាក់ទិននឹងអង្គហេតុស្តីអំពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាម។ យោងតាមមេធាវីការពារក្តី នួន ជា ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-234 បង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-300 អាចត្រូវបានគេបង្ខំឱ្យសម្លាប់ប្រពន្ធជនជាតិវៀតណាមរបស់គាត់ ហើយហេតុការណ៍នេះត្រូវបានដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-300 បដិសេធនៅក្នុងចម្លើយពីមុនរបស់គាត់ (ប្រតិចារឹកសវនាការ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ២-១០, ឯកសារ E3/4732, ឯកសារ E3/4989)។ អង្គជំនុំជម្រះបានសម្រេចកោះហៅដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-234 តាមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីផ្តល់ឱកាសឱ្យមេធាវីការពារក្តី នួន ជា បញ្ជាក់ឱ្យច្បាស់អំពីសំណួររបស់ខ្លួនដែលបានលើកឡើងពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-300 នេះ(សូមមើល អ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥)។ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានព្យាយាមប្រគល់ដីកាកោះជូនទៅដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែមិនបានសម្រេចឡើយ។

៧. ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៦ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ បានដាក់របាយការណ៍ជូនអង្គជំនុំជម្រះសាលាដំបូង ដោយបានពិពណ៌នាលម្អិតអំពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនរហូតមកដល់បច្ចុប្បន្នដើម្បីធានានូវវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ(ឯកសារE29/480)។ យោងតាមរបាយការណ៍នេះ អង្គភាពគាំពារសាក្សី និង អ្នកជំនាញបានទំនាក់ទំនងជាទៀងទាត់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-234 ដោយផ្ទាល់ ឬ តាមរយៈសហមេធាវីនាំមុខអស់រយៈពេលប្រហែល ៥ ខែ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ គឺអ្នកស្រី Lyma Nguyen មិនអាចទំនាក់ទំនងជាមួយដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-234 បានទេ។ នៅក្នុងអំឡុងរយៈពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះកំពុងស្នាក់នៅប្រទេសវៀតណាម និងបញ្ជាក់ថា សុខភាពរបស់គាត់ទន់ខ្សោយមែនទែន មិនអាចធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការបានទេ។ ទោះបីពីដំបូងគាត់បានសន្យាថាផ្តល់លិខិតបញ្ជាក់សុខភាពជូនតុលាការក៏ដោយ ក៏ដើមបណ្តឹងរូបនេះមិនបានធ្វើតាមការសន្យានេះឡើយ ដោយផ្តល់ហេតុផលថា "មានការលំបាកក្នុងការស្នើសុំលិខិតបញ្ជាក់សុខភាព"។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏បានបញ្ជាក់ផងដែរថា គាត់កំពុងជួបប្រទះបញ្ហាថវិកា ហើយថា គាត់មិនចង់មកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក ទេ។ អង្គភាពគាំពារសាក្សី និង អ្នកជំនាញមិនមានលទ្ធភាពទទួលបានអាសយដ្ឋានច្បាស់លាស់របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងប្រទេសវៀតណាមបានទេ (ឯកសារ E29/480 ទំព័រ ១-៤)។

៨. អង្គភាពគាំពារសាក្សី និង អ្នកជំនាញសន្និដ្ឋានថា អង្គភាពគាំពារសាក្សី និង អ្នកជំនាញទំនងជាមិនអាចបន្តអនុវត្តភារកិច្ចទៅមុខទៀតដើម្បីទទួលបានកិច្ចសហការពីគាត់ ឬ ទទួលបានលិខិតបញ្ជាក់សុខភាពរបស់គាត់ឡើយ វៀរលែងតែដើមបណ្តឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់មកកម្ពុជាវិញ (ឯកសារ E29/480 ទំព័រ ៤)។

៩. អង្គជំនុំជម្រះយល់ឃើញថា ដោយសារតែពុំមានព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងច្បាស់លាស់នៅក្នុងប្រទេសវៀតណាមនោះ សំណើសុំឱ្យអាជ្ញាធរវៀតណាមស្វែងរក និង កោះហៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ទំនងជាមិនអាចទទួលបានជោគជ័យ នៅក្នុងពេលវេលាសមស្របឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-234 មិនអាចធ្វើទៅបានឡើយនៅក្នុងពេលវេលាសមស្រប ហើយអង្គជំនុំជម្រះសម្រេចដកដីកាកោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះចេញវិញ។